# ការវាយតម្លៃបឋម

## ប្រកាសស្តីពីការគ្រប់គ្រងសំណល់រាវដែលមានសារធាតុគីមីពុល

## ក្រសួងបរិស្ថាន (MoE)

លេខយោង : ០០០០១៤ / System no. 36

កាលបរិច្ឆេទចាប់ផ្តើម : ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១២

កាលបរិច្ឆេទបញ្ចប់ : ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៣

ប្រកាសបញ្ជាក់ពីគោលការណ៍ណែនាំដែលត្រូវអនុវត្តដោយរោងចក្រសិប្បកម្មដែលមានសំណល់រាវមានសារធាតុគីមីពុល។ គោលការណ៍ណែនាំបញ្ជាក់ពីការរៀបចំរចនានិងការតម្លើងមធ្យោបាយប្រព្រឹត្តិកម្មដែលត្រូវប្រើប្រាស់ និងកម្រិតជាតិពុលនៃសំណល់រាវដែលអាចបញ្ចេញចោលទៅក្នុងប្រព័ន្ធលូឬផ្លូវទឹកសាធារណៈ។ ទណ្ឌកម្មនឹងត្រូវអនុវត្តចំពោះការមិនគោរពតាម។ ប្រកាសនឹងគាំទ្រច្បាប់ដែលមានស្រាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់និងកិច្ចការពារបរិស្ថាន ដោយបញ្ជាក់លម្អិតពីរបៀបធ្វើឲ្យសម្រេចនូវការត្រួតពិនិត្យការបំពុលប្រកបដោយប្រសិទ្ធភាព។

ទោះបីជា ច្បាប់និងអនុក្រឹត្យដែលមានស្រាប់សម្រាប់ការត្រួតពិនិត្យការបំពុលទឹក ក៏ការបញ្ចេញចោលសំណល់រាវដែលមានសារធាតុគីមីប្រកបដោយគ្រោះថ្នាក់ ដែលបំផ្លាញបរិស្ថានចូលទៅក្នុងផ្លូវទឹកនៅតែកើតមានឡើង។ កត្តាមួយនៃបញ្ហានេះ គឺការលំបាកក្នុងការជំរុញឲ្យមានស្តង់ដារសមស្រប ដោយផ្អែកទៅលើការតម្រូវនៃការគ្រប់គ្រងសំណល់ទូទៅ ដែលអាចអនុញ្ញាតឲ្យម្ចាស់នៃប្រភពបំពុលកំណត់វិធីប្រព្រឹត្តិកម្មដោយខ្លួនឯង។

គោលបំណងនៃប្រកាសនេះ គឺកាត់បន្ថយការបញ្ចេញចោលសំណល់រាវដែលមានសារធាតុគីមីបង្កគ្រោះថ្នាក់ពីរោងចក្រចូលទៅក្នុងផ្លូវទឹក ឲ្យនៅកម្រិតស្របនឹងស្តង់ដាដែលមានចែងនៅក្នុងអនុក្រឹត្យស្តីពីការត្រួតពិនិត្យ ដើម្បីកាត់បន្ថយជាអតិបរិមានូវផលប៉ះពាល់អវិជ្ជមានទៅលើបរិស្ថាន រួមមានការខូចសុខភាពមនុស្ស សត្វ និងជីវចម្រុះ។

សេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យការបំពុលបរិស្ថាន និងសេចក្តីព្រាងច្បាប់ស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថានកំពុងត្រូវបានរៀបចំ ដើម្បីពង្រឹងរបបទណ្ឌកម្មដែលមានស្រាប់និងធ្វើឲ្យមានការគោរពតាមលក្ខខណ្ឌតម្រូវចំពោះការការពារបរិស្ថាន ប្រកាសនេះត្រូវបានវាយតម្លៃ ស្របនឹងសេចក្តីព្រាងច្បាប់ថ្មីទាំងពីរនេះដែរ ដើម្បីកំណត់ថាតើគួរបង្កើតប្រកាសឬយ៉ាងណា។ ម្យ៉ាងទៀត ប្រកាសក៏ត្រូវបានវាយតម្លៃធៀបទៅនឹងជម្រើសមួយចំនួនទៀត ។ ជម្រើសផ្សេងទៀត ដូចជាការ

អប់រំនិងការបង្កើនការយល់ដឹងជាសាធារណៈ និងការផ្តល់គោលការណ៍ណែនាំបច្ចេកទេសដោយស្ម័គ្រចិត្ត ត្រូវបានពិចារណាថា ជាជម្រើសមិនអាចអនុវត្តបាន សម្រាប់ការផ្លាស់ប្តូរឥរិយាបថ។ ជម្រើសនីមួយៗអាចមានបន្ទុកចំណាយកាតព្វកិច្ចច្រើនគួរឲ្យកត់សម្គាល់ ដោយតម្រូវឲ្យធុរកិច្ចកែលម្អមធ្យោបាយគ្រប់គ្រងសំណល់របស់ពួកគេ ហួសពីលក្ខខណ្ឌតម្រូវជាមូលដ្ឋានរបស់ច្បាប់ដែលមានស្រាប់ ដើម្បីជៀសវាងការបំពុលផ្លូវទឹក។ ការវាយតម្លៃលើផលប៉ះពាល់សន្និដ្ឋានថា មានផលចំណេញច្រើនគួរឲ្យកត់សម្គាល់ពីការបង្កើតប្រកាសនេះ ដោយការកាត់បន្ថយហានិភ័យនៃការបំពុលទឹកប្រកបដោយគ្រោះថ្នាក់ ទោះបីជាយ៉ាងណា បន្ទុកចំណាយអាចមានច្រើនគួរឲ្យកត់សម្គាល់ ការវាយតម្លៃពេញលេញ(RIS)គួរត្រូវបានរៀបចំ។

# ការវាយតម្លៃបឋម

## ប្រកាសស្ដីពីការគ្រប់គ្រងសំណល់រាវដែលមានសារធាតុគីមីពុល

## ក្រសួងបរិស្ថាន (MoE)

លេខយោង : ០០០០១៤ / System no. 36

កាលបរិច្ឆេទចាប់ផ្ដើម : ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១២

កាលបរិច្ឆេទបញ្ចប់ : ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៣

ទំនាក់ទំនង :

| | ឈ្មោះ | តួនាទី | លេខទូរស័ព្ទ | Email |
|---|---|---|---|---|
| IA | ឯកឧត្តម ឈុន វណ្ណៈ | ប្រធាន RIA | 012 792 494 | vannakdrchhun@gmail.com |
| | លោក យិន សំរាយ | អនុប្រធាន RIA | 011 87 15 41<br>097 752 56 77 | yinsamray@gmail.com |
| | លោក ម៉ុក ច័ន្ទករុណា | សមាជិក | 089 900 789 | mok.chankarona@yahoo.com |
| | លោក រស់ ជ័រ | សមាជិក | 012 98 60 98 | roschor@gmail.com |
| ORIA | ឯកឧត្តម អេង រត្នមុនី | ប្រធាន RIA | 012 91 2009 | ratmoni@yahoo.com |
| | ឯកឧត្តម ម៉ម សារិទ្ធ | ប្រធាន CBA | 012 66 23 16 | mamsarith@yahoo.com |
| | លោកស្រី លឹម សុគន្ធា | ទទួលបន្ទុក | 092 73 69 69 | lskthea@yahoo.com |
| | លោក ជា ពិសិដ្ឋនរៈ | ជំនួស | 012 90 81 61 | ps_norak@yahoo.com |

### អត្ថាធិប្បាយសង្ខេបអំពីសំណើបញ្ញត្តិកម្ម

ប្រកាសនេះនឹងតម្រូវឲ្យរោងចក្រសំអាតសំណល់រាវដែលមានសារធាតុគីមីពុល ដោយអនុលោមតាមគោលការណ៍បច្ចេកទេស មុនពេលបញ្ចេញចោលទៅក្នុងប្រព័ន្ធលូសាធារណៈ និងប្រភពទឹកសាធារណៈ សំដៅធានាឲ្យបាននូវការការពារសុខភាពមនុស្ស សត្វ និងការអភិរក្សជីវៈចម្រុះ។ គោលការណ៍បច្ចេកទេសនេះបញ្ជាក់ពីឧបករណ៍សម្ភារៈប្រព្រឹត្តិកម្មចាំបាច់នានាសម្រាប់សំអាតសំណល់រាវដែលមានសារធាតុគីមីពុល និងបញ្ជាក់ពីកម្រិតសារធាតុគីមីដែលមាននៅក្នុងសំណល់រាវ ដែលអាចបញ្ចេញចោលបាន។

ក្រសួងបរិស្ថាននឹងធ្វើអធិការកិច្ចក្រុមហ៊ុនដែលបញ្ចេញសំណល់រាវដែលមានសារធាតុគីមីពុល លើសពីកម្រិតកំណត់ និងផាកពិន័យចំពោះរោងចក្រ សហគ្រាសណា ដែលមិនអនុវត្តតាម។ 84

តើសំណើនេះមានចរិកជាបញ្ញត្តិកម្មដែរឬទេ?

តើវាផ្លាស់ប្តូរឥរិយាបទធុរកិច្ចដែរឬទេ? មែន

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ច្បាប់ | | ព្រះរាជក្រឹត្យ | | អនុក្រឹត្យ | | ប្រកាស | ✓ | សេចក្តីសម្រេច | | សារាចរ | | ផ្សេងៗ |

តើសំណើបញ្ញត្តិនេះមានផលប៉ះពាល់លើវិស័យធុរកិច្ចដែរឬទេ? មែន

## ១. បញ្ហា- ហេតុអ្វីបានជាយើងធ្វើបញ្ញត្តិនេះឡើង?

| ប្រធានបទទូទៅ | | ភស្តុតាង/ភាពជាក់ស្តែង (សូមភ្ជាប់កំណត់សម្គាល់ ប្រសិនបើចាំបាច់) |
|---|---|---|
| សុខភាព និង សុវត្ថិភាពសាធារណៈ | មែន | ការបញ្ចេញសំណល់រាវដែលមានសារធាតុគីមីពុល បង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស សត្វ និងជីវៈចម្រុះ ។<br>ឧទាហរណ៍៖<br>–នៅខែសីហា ឆ្នាំ២០០៩ មានរោងចក្រចម្រាញ់អេតាណុល ជីវៈមួយបានបញ្ចេញសារធាតុពុល(អាម៉ូញ៉ាក់)ចូលទៅក្នុងទន្លេ បានសម្លាប់ត្រីអស់ចំនួន៦៣តោន។<br><br>–នៅឆ្នាំ២០០៣-២០០៤ មានករណីគ្រោះថ្នាក់នៅភូមិស្នួងអង ទឹកទន្លេបានប្រែពណ៌ បណ្តាលឲ្យមនុស្ស២នាក់ និងគោ២ក្បាលបានស្លាប់ដោយសារផឹកទឹកទន្លេដែលរងការបំពុល។ (របាយការណ៍ស្តីពីការគ្រប់គ្រងសាធាតុគីមីនៅកម្ពុជា ខែធ្នូ ឆ្នាំ២០០៩) ។<br>–នៅតំបន់ព្រំដែនកម្ពុជា-វៀតណាម ត្រពាំងផ្លុង កាស៊ីណូបានបង្ហូរសំណល់រាវមានជាតិពុលចូលទៅក្នុងព្រែកមួយ ដែលធ្វើឲ្យមានការថយចុះផលនេសាទ។ ត្រីដែលនេសាទបានមានក្លិនសាប៊ូ មិនអាចបរិភោគបាន។ (ប្រភព:កាសែតរស្មី កម្ពុជា ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២) ។ |
| ការការពារ និង អភិរក្សបរិស្ថាន | មែន | សំណល់រាវដែលមានសារធាតុគីមី ធ្វើឲ្យប៉ះពាល់ដល់សារភ័ណភាព ប្រពភទឹកសាធារណៈមានក្លិនមិនល្អ ។ល។<br>សារធាតុគីមីពុលប្រកបដោយគ្រោះថ្នាក់ ដូចជា ក្លុយអរ ផូស្វរ បារត អ៊ីដ្រូកាបូ ស៊ីលីស្យូម អាម៉ូញ៉ាក់ នីទ្រីត.... អាចធ្វើឲ្យទឹក និងដីខូចគុណភាព ព្រមទាំងបង្កគ្រោះថ្នាក់ដល់ជីវិតមនុស្ស សត្វ និងជីវៈចម្រុះ។ |

| | | |
|---|---|---|
| សមធម៌យេនឌ័រ ការអភិវឌ្ឍសង្គម និង វប្បធម៌ | មិនមែន | |
| ជម្រុញការប្រកួតប្រជែង | មិនមែន | |
| ការប្រមូលផ្តុំព័ត៌មាន | មិនមែន | |
| អនុលោមតាមកិច្ចព្រមរបស់(WTO) និងកិច្ចព្រមព្រៀងអន្តរជាតិនានា | មែន | ប្រទេសកម្ពុជាជាភាគីហត្ថលេខីនៃអនុសញ្ញាស្តុកខូមស្តីពី សារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ។ |

## ប្រសិនបើមានបញ្ហាផ្សេងទៀត ចូរពន្យល់ និងផ្តល់ភស្តុតាង

ប្រភពទឹកដែលមានសារធាតុគីមីពុលនឹងបង្កផលប៉ះពាល់អវិជ្ជមានដល់វិស័យទេសចរណ៍ ។

## សូមបញ្ជាក់ថាតើបញ្ញត្តិកម្មនេះ នឹងធ្វើឲ្យស្ថានការណ៍ប្រសើរឡើងយ៉ាងដូចម្តេច

ប្រកាសនេះនឹងបញ្ជាក់ពីគោលការណ៍បច្ចេកទេស សម្រាប់ការតម្លើងឧបករណ៍សម្ភារៈ ប្រព្រឹត្តកម្ម និងយន្តការពង្រឹងការអនុវត្តន៍ ដើម្បីធានាឲ្យមានការយល់ដឹង និងទទួលយកនូវវិធីសាស្ត្រប្រព្រឹត្តិកម្មសមរម្យ។

## ២. គោលបំណង - តើយើងចង់សម្រេចអ្វី?

កាត់បន្ថយសារធាតុគីមីពុលនៅក្នុងសំណល់រាវដែលបញ្ចេញចោលដោយរោងចក្រឧស្សាហកម្មទៅក្នុងផ្លូវទឹក ឲ្យនៅក្នុងកម្រិតមួយដែលអនុលោមទៅតាមស្តង់ដាដែលមានចែងនៅក្នុងអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក ដើម្បីកាត់បន្ថយជាអតិបរមានូវផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន ដែលជាបច្ច័យអាក្រក់ដល់សុខភាពមនុស្ស សត្វ និងជីវៈចម្រុះ។

## ៣. ជម្រើស- ពិចារណាជម្រើសផ្សេងៗទាំងឡាយ

### ៣.ក. សូមរាយបញ្ជីបញ្ញត្តិកម្ម(ដែលមានស្រាប់) ដែលពាក់ព័ន្ធ ឬប្រហាក់ប្រហែល

| |
|---|
| ១. ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦។ |
| ២. អនុក្រឹត្យលេខ២៧ ស្តីពី ការត្រួតពិនិត្យការបំពុលទឹក ឆ្នាំ១៩៩៩។ |
| ២. អនុក្រឹត្យលេខ៣៦ ស្តីពី ការគ្រប់គ្រងសំណល់រឹង ឆ្នាំ១៩៩៩។ |
| ៣. អនុក្រឹត្យលេខ៧២ ស្តីពី កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឆ្នាំ១៩៩៩។ |
| ៤. ច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ |

### ចូរបញ្ជាក់ថាតើហេតុអ្វី បានជាលិខិតបទដ្ឋានទាំងនេះ មិនទាន់គ្រប់គ្រាន់?

ប្រជាជនកម្ពុជា និងសេដ្ឋកិច្ចជាតិមានការកើនឡើងគួរឲ្យកត់សម្គាល់ ទន្ទឹមនឹងនោះការសាងសង់រោងចក្រក៏កាន់តែមានច្រើន ឧទាហរណ៍ នៅរាជធានីភ្នំពេញមានរោងចក្រចំនួន២៨ និងខេត្តកណ្តាលចំនួន ១០ រោងចក្រប្រើប្រាស់សារធាតុគីមី ហើយបានតម្លើងឧបករណ៍សម្ភារៈប្រព្រឹត្តិកម្មលើសពីនោះទៀត មានសកម្មភាពផ្សេងទៀតដូចជា ការធ្វើអាជីវកម្មរ៉ែក៏កំពុងតែកើនឡើងដែរ។

ធុរកិច្ចមួយចំនួនគោរពតាមច្បាប់និងអនុក្រឹត្យបានតិចតួចប៉ុណ្ណោះ ឧទាហរណ៍ អាជីវកម្មរ៉ែខ្លះមិនមានឧបករណ៍សម្ភារៈប្រព្រឹត្តិកម្មគ្រប់គ្រាន់ទេ ដែលអាចបង្កឲ្យមានបញ្ហាកើតឡើង។
លិខិតបទដ្ឋានដែលមានស្រាប់ គឺមានលក្ខណៈទូទៅ ពុំមានចែងពីគោលការណ៍បច្ចេកទេសស្តីពីការសំអាតសំណល់រាវដែលមានសារធាតុគីមី។ តាមបទពិសោធរបស់ក្រសួងបរិស្ថាន ការគោរពតាមច្បាប់នៅមានកម្រិតទាប នៅពេលដែលច្បាប់ទាំងនោះមានលក្ខណៈទូទៅ ផ្ទុយទៅវិញ ការមានគោលការណ៍ណែនាំបន្ថែម នឹងធ្វើឲ្យមានការគោរពតាមច្បាប់បានច្រើនជាងមុន និងការពង្រឹងការអនុវត្តន៍ច្បាប់កាន់តែមានប្រសិទ្ធភាព។

ម្យ៉ាងទៀត ការធ្វើតេស្តសំណល់រាវដែលត្រូវបញ្ចេញចោលពីរោងចក្រមិនទាន់គ្រប់គ្រាន់ទេ ពីព្រោះរោងចក្រនៅតែអាចដឹកជញ្ជូនសំណល់រាវទៅចាក់ចោលនៅកន្លែងផ្សេងទៀតបាន។

ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិដាក់កម្រិតទណ្ឌកម្មស្រាលចំពោះការបំពុលបរិស្ថាន ដូច្នេះបន្ទុកចំណាយលើការបង់ពិន័យទាបជាងបន្ទុកចំណាយលើការសំអាតសំណល់រាវដែលអាចបំផ្លាញបរិស្ថាន។ តាមច្បាប់នេះ ឧស្សាហករ នៅតែបន្តបំពុលបរិស្ថានដោយគ្មានញញើតចំពោះការបង់ប្រាក់ពិន័យដែលមានចំនួនតិចតួច។

ជម្រើសផ្សេងៗ

## ៣.ខ. ជម្រើសផ្សេងៗដែលអាចអនុវត្តបាន (សម្រាប់ការវិភាគលើផលប៉ះពាល់)

១.សំណើប្រកាស : កំណត់គោលការណ៍ណែនាំបច្ចេកទេសចំពោះឧបករណ៍សម្ភារៈ ឬមធ្យោបាយប្រព្រឹត្តិកម្ម។

២.បង្កើនទណ្ឌកម្ម : ស្នើដាក់បញ្ចូលក្នុងសេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យការបំពុលបរិស្ថាន។ សេចក្តីព្រាងច្បាប់នេះចែងពីលក្ខខ័ណ្ឌតម្រូវទូលំទូលាយក្នុងការត្រួតពិនិត្យការបំពុល ដែលជាទូទៅស្របនឹងកាតព្វកិច្ចដែលមានស្រាប់ ក៏ប៉ុន្តែ នឹងចែងពីការបង្កើនទណ្ឌកម្ម រួមទាំងទោសជាប់ពន្ធនាគារ។

៣.បង្កើនទណ្ឌកម្ម និង ធ្វើការវាយតម្លៃផលប៉ះពាល់បរិស្ថានឲ្យបានម៉ត់ចត់ជាងមុន : ស្នើដាក់បញ្ចូលក្នុងសេចក្តីព្រាងច្បាប់ស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន(EIA)។ សេចក្តីព្រាងច្បាប់នេះពង្រឹងនិងពង្រីកអនុក្រឹត្យ EIA ដែលកំពុងអនុវត្តបច្ចុប្បន្ន ដោយបង្កើនទណ្ឌកម្មនិងពង្រីកវិសាលភាពដែលត្រូវវាយតម្លៃផលប៉ះពាល់។

៤.បង្កើនការធ្វើអធិការកិច្ចនិងឲ្យបានតឹងរឹងជាងមុន ដោយផ្អែកលើលក្ខខណ្ឌតម្រូវដែលមានស្រាប់។

## ៣.គ. ជម្រើសផ្សេងៗដែលតាមទ្រឹស្តីអាចមាន ប៉ុន្តែមិនអាចអនុវត្តបាន

៥.យុទ្ធនាការអប់រំ និងលើកកម្ពស់ការយល់ដឹងជាសាធារណៈ។ ជម្រើសនេះមិនអាចអនុវត្តបានទេ ពីព្រោះម្ចាស់រោងចក្រនឹងមិនមានឆន្ទៈក្នុងការអនុវត្តតាម ដោយសារ មិនមានការចាប់បង្ខំ។ ម៉្យាងវិញទៀតម្ចាស់រោងចក្រអាចនឹងគិតពីប្រយោជន៍ផ្ទាល់ខ្លួនច្រើនជាងកិច្ចការពារបរិស្ថាន ដែលជាប្រយោជន៍ដល់សង្គមទាំងមូល ។

៦.លើកទឹកចិត្តដល់រោងចក្រឲ្យអនុវត្តតាមលក្ខខណ្ឌបច្ចេកទេសក្នុងការសំអាតសំណល់រាវដែលមានសារធាតុគីមីពុល តាមរយៈការផ្តល់វិញ្ញាបនបត្រទទួលស្គាល់បរិស្ថានស្អាតបង្ហាញនៅលើផលិតផល និងសេវាកម្មរបស់ពួកគេ ។ ជម្រើសនេះអាចអនុវត្តបាន ចំពោះក្រុមហ៊ុនខ្លះដែលមានកិត្តិយសបារម្ភពីកេរ្តិ៍ឈ្មោះផ្នែកបរិស្ថានរបស់ខ្លួនជាមួយនឹងអតិថិជន ក៏ប៉ុន្តែ ជម្រើសនេះចាត់ទុកថាមិនអាចអនុវត្តបាន។ នេះដោយសារ ធុរកិច្ចខ្លះដែលមានសំណល់រាវ ដូចជា ក្រុមហ៊ុនអាជីវកម្មរ៉ែ មិនចាប់អារម្មណ៍នឹងវិញ្ញាបនបត្រទទួលស្គាល់បរិស្ថានស្អាតនោះទេ ពីព្រោះផលិតផលរបស់ពួកគេមិនត្រូវបានលក់ដោយផ្ទាល់ទៅអតិថិជនទេ ហើយវាក៏មិនផ្តល់អត្ថប្រយោជន៍ខាងផ្នែកផ្សព្វផ្សាយរកទីផ្សារដែរ។ ចំពោះធុរកិច្ចបែបនេះ ការចំណាយច្រើនលើប្រព្រឹត្តកម្មសំណល់រាវដែលមានសារធាតុគីមីនឹងអាចធ្វើឲ្យថ្លៃផលិតផលរបស់ពួកគេខ្ពស់ជាងមុន ហើយធ្វើឲ្យផលិតផលទាំងនោះមានភាពប្រកួតប្រជែងខ្សោយជាងមុននៅលើទីផ្សារ។

## ៤. ការប៉ាន់ស្មានបឋមចំណាយភាគពួកិច្ច និងផលប៉ះពាល់ចំពោះការប្រជែង

### ៤.១. ការកំណត់នូវភារកិច្ច និងប្រភេទចំណាយ

| អត្ថាធិបាយអំពីជម្រើស | ភារកិច្ច និងប្រភេទចំណាយដែលវិស័យសាធារណៈត្រូវរ៉ាប់រងដើម្បីបង្កើត អនុវត្ត និងប្រតិបត្តិជម្រើសនោះ | ភារកិច្ច និងប្រភេទចំណាយដែលវិស័យឧស្សាហកម្មត្រូវរ៉ាប់រងដើម្បីអនុវត្តតាមជម្រើសនោះ |
|---|---|---|
| ជម្រើសទី១: ប្រកាស | -ការបង្កើតនិងបណ្តុះបណ្តាលក្រុមអធិការ។<br>-ការធ្វើអធិការកិច្ចលើបច្ចេកទេស(សកម្មភាពត្រូវអនុវត្តបន្ត) | -កសាងឧបករណ៍សម្ភារៈឬមធ្យោបាយប្រព្រឹត្តិកម្មសំណល់រាវឲ្យស្របតាមគោលការណ៍ណែនាំដែលមានចែងនៅក្នុងប្រកាស។<br>-ប្រតិបត្តិការសំអាតសំណល់រាវ(សកម្មភាពត្រូវអនុវត្តបន្ត)<br>-ទទួលការធ្វើអធិការកិច្ច(សកម្មភាពត្រូវអនុវត្តបន្ត) |
| ជម្រើសទី២ : បង្កើនទណ្ឌកម្ម (សេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យការបំពុលបរិស្ថាន) | -ការបណ្តុះបណ្តាលបឋមដល់មន្ត្រីចំពោះច្បាប់ថ្មី<br>-មិនការផ្លាស់ប្តូរត្រូវធ្វើបន្តនោះទេ | -មិនការផ្លាស់កាតព្វកិច្ចទេ ក៏ប៉ុន្តែអាចបង្កើនកម្រិតនៃការអនុវត្តន៍តាម ដូច្នេះជំរុញឲ្យធុរកិច្ចទទួលរងបន្ទុកចំណាយកាតព្វកិច្ចបន្ថែមទៀត |
| ជម្រើសទី៣ : បង្កើនទណ្ឌកម្ម និង ធ្វើការវាយតម្លៃផលប៉ះពាល់បរិស្ថានឲ្យបានម៉ត់ចត់ជាងមុន | -បង្កើតក្រុមការងារអនុវត្ត<br>-ការបណ្តុះបណ្តាលបឋមដល់មន្ត្រីចំពោះច្បាប់ថ្មី<br>-ដំឡើងនាយកដ្ឋានEIAទៅជាអគ្គនាយកដ្ឋាន<br>-បន្ថែមមន្ត្រីនិងបង្កើនការធ្វើ | -បញ្ជ្រាបការយល់ដឹងច្បាប់ថ្មី<br>-បន្ទុកចំណាយបន្ថែមលើការវាយតម្លៃបរិស្ថានចំពោះគម្រោងថ្មីម៉ត់ចត់ និងច្បាស់លាស់ជាងមុន<br>-ការដាក់ទណ្ឌកម្មធ្ងន់ធ្ងរអាចធ្វើឲ្យមានការអនុវត្តន៍តាមច្រើនជាងមុន ហើយដូច្នេះ |

| | | |
|---|---|---|
| (សេចក្ដីព្រាងច្បាប់ EIA) | អធិការកិច្ចនិងពង្រឹងការអនុវត្តច្បាប់ | ចំណាយកាតព្វកិច្ចកើនឡើង |
| ជម្រើសទី៤ : បង្កើនការធ្វើអធិការកិច្ចនិងឲ្យបានតឹងរឹងជាងមុនដោយផ្អែកលើលក្ខខណ្ឌតម្រូវដែលមានស្រាប់ | -តែងតាំងអធិការបន្ថែមទៀត<br>-ធ្វើអធិការកិច្ចច្រើនជាងមុន | -ទទួលការធ្វើអធិការកិច្ចច្រើនជាងមុន<br>-អាចតម្លើងឧបករណ៍សម្ភារៈឬមធ្យោបាយប្រព្រឹត្តកម្មសំណល់រាវស្របតាមការណែនាំរបស់អធិការ<br>-ប្រតិបត្តិការសំអាតសំណល់រាវ(សកម្មភាពត្រូវអនុវត្តបន្ត) |

## ៤.២. វិសាលភាពនៃជម្រើស

| ជម្រើស | វិស័យធុរកិច្ច | ចំនួនធុរកិច្ច | ឯកសារយោង/ភស្តុតាង |
|---|---|---|---|
| ជម្រើសទី១: ប្រកាស | ធុរកិច្ចណាដែលបញ្ចេញសំណល់រាវដែលមានសារធាតុគីមីពុលកម្រិតខ្ពស់ | ៥០(ប៉ាន់ស្មាន) | ប្រមាណ ៥% នៃធុរកិច្ចខ្នាតធំនិង SMEs មួយចំនួន(មិនច្បាស់ពីចំនួន)ត្រូវបានគេគិតថា មិនមានឧបករណ៍សម្ភារៈឬមធ្យោ បាយប្រព្រឹត្តិកម្មគ្រប់គ្រាន់នៅឡើយទេ ដូច្នេះចាំបាច់ត្រូវតម្លើងនិងប្រតិបត្តិការឧបករណ៍សម្ភារៈថ្មីដែលត្រូវតម្លើងបន្ថែមនេះ |
| ជម្រើសទី២ : បង្កើនទណ្ឌកម្ម(សេចក្ដីព្រាងច្បាប់ស្ដីត្រួតពិនិត្យការបំពុលបរិស្ថាន) | គ្រប់ធុរកិច្ចទាំងអស់ | | សេចក្ដីព្រាងច្បាប់ថ្មីនេះនឹងអនុវត្តចំពោះធុរកិច្ចទូទៅ. |

| | | | |
|---|---|---|---|
| ជម្រើសទី៣ : បង្កើនទណ្ឌកម្ម និងធ្វើការវាយតម្លៃផលប៉ះពាល់បរិស្ថានឲ្យបានម៉ត់ចត់ជាងមុន(សេចក្តីព្រាងច្បាប់EIA) | គ្រប់ធុរកិច្ចទាំងអស់ | | គ្រប់ធុរកិច្ចទាំងអស់នឹងត្រូវទទួលរងនូវទណ្ឌកម្មខ្លាំងជាងមុនតាមសេចក្តីព្រាងច្បាប់នេះ។ បើតាមគោលការណ៍ណែនាំថ្មី ធុរកិច្ចទាំងអស់នឹងត្រូវអនុវត្តEIAតឹងតែងនិងច្បាស់លាស់ជាងមុន។ |
| ជម្រើសទី៤ : បង្កើនការធ្វើអធិការកិច្ចនិងឲ្យបានតឹងរឹងជាងមុន ដោយផ្អែកលើលក្ខខណ្ឌតម្រូវដែលមានស្រាប់ | ធុរកិច្ចណាដែលមានសំណល់រាវមានសារធាតុគីមីពុលកម្រិតខ្ពស់ | ១០០(ប៉ាន់ស្មាន) | ជម្រើសនេះនឹងអនុវត្តចំពោះធុរកិច្ចដែលមាននិងមិនមានឧបករណ៍សម្ភារៈឬមធ្យោបាយប្រព្រឹត្តកម្ម |

## ៤.៣. ប៉ាន់ស្មានកម្រិតកំណើននៃចំណាយកាតព្វកិច្ចរបស់ធុរកិច្ច និងរបស់រាជរដ្ឋាភិបាល

| ជម្រើស | កម្រិតចំណាយកាតព្វកិច្ច | អំណះអំណាង(មើលទំព័រខាងក្រោយ) |
|---|---|---|
| ជម្រើសទី១ : ប្រកាស | គួរឲ្យកត់សម្គាល់ | ៥លានដុល្លារ ដូចដែលបានប៉ាន់ស្មាននៅក្នុងទំព័រភ្ជាប់ គឺជាបន្ទុកចំណាយកាតព្វកិច្ចខ្ពស់។ |
| ជម្រើសទី២ : បង្កើនទណ្ឌកម្ម(សេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យការបំពុលបរិស្ថាន) | គួរឲ្យកត់សម្គាល់ | ស្រដៀងនឹងសំណើប្រកាស ធុរកិច្ចអាចទទួបន្ទុកចំណាយខ្ពស់ ដើម្បីត្រួតពិនិត្យសំណល់រាវដែលមានសារធាតុគីមីពុល។ បន្ទុកចំណាយអាចស្រដៀងនឹងជម្រើសទី១។ |
| ជម្រើសទី៣ : បង្កើនទណ្ឌកម្ម និង ធ្វើការវាយតម្លៃផលប៉ះពាល់ | គួរឲ្យកត់សម្គាល់ | ស្រដៀងនឹងសំណើប្រកាស ធុរកិច្ចអាចទទួបន្ទុកចំណាយខ្ពស់ ដើម្បីត្រួតពិនិត្យសំណល់រាវដែលមានសារធាតុគីមីពុល។ បន្ទុកចំណាយអាច |

| | | |
|---|---|---|
| បរិស្ថានឲ្យបានម៉ត់ចត់ជាងមុន (សេចក្ដីព្រាងច្បាប់EIA) | | ស្រដៀងនឹងជម្រើសទី១។ |
| ជម្រើសទី៤ : បង្កើនការធ្វើអធិការកិច្ចនិងឲ្យបានតឹងរឹងជាងមុន ដោយផ្អែកលើលក្ខខណ្ឌតម្រូវដែលមានស្រាប់ | គួរឲ្យកត់សម្គាល់ | ការបង្កើនចំនួនអធិការកិច្ចត្រូវបានគេរំពឹងថានឹងមានការអនុវត្តន៍តាមលក្ខខណ្ឌតម្រូវដែលមានស្រាប់ច្រើនជាងមុន បើធៀបនឹងស្ថានភាពបច្ចុប្បន្ន។ ករណីនេះ នឹងតម្រូវឲ្យធុរកិច្ចវិនិយោគបន្ថែមលើឧបករណ៍សម្ភារៈឬមធ្យោបាយប្រព្រឹត្តកម្ម។ ការចំណាយលើវិនិយោគបន្ថែមនេះអាចមានកម្រិតប៉ាន់ស្មានដូចជម្រើសទី១។ |
| **រាជរដ្ឋាភិបាល** | **កម្រិតកំណើននៃចំណាយ កាតព្វកិច្ច** | **អំណះអំណាង** |
| ជម្រើសទី១ : ប្រកាស | មិនគួរឲ្យកត់សម្គាល់ | ៣៥ ៦០០ ដុល្លារ ដូចដែលបានប៉ាន់ស្មាននៅក្នុងទំព័រភ្ជាប់ ប្រហែលជា៣%នៃថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋានត្រួតពិនិត្យការបំពុល។ |
| ជម្រើសទី២ : បង្កើនទណ្ឌកម្ម(សេចក្ដីព្រាងច្បាប់ស្ដីពីការត្រួតពិនិត្យការបំពុលបរិស្ថាន) | មិនគួរឲ្យកត់សម្គាល់ | ពាក់ព័ន្ធតែនឹងការបណ្ដុះបណ្ដាលបឋមដល់មន្ត្រី។ ពុំមានសកម្មភាពត្រូវអនុវត្តបន្ត និងបន្ទុកចំណាយគួរឲ្យកត់សម្គាល់ទេ។ |
| ជម្រើសទី៣ : បង្កើនទណ្ឌកម្ម និង ធ្វើការវាយតម្លៃផលប៉ះពាល់បរិស្ថានឲ្យបានម៉ត់ចត់ជាងមុន (សេចក្ដីព្រាងច្បាប់EIA) | គួរឲ្យកត់សម្គាល់ | -ការបណ្ដុះបណ្ដាលបឋមនិងចំណាយលើការអនុវត្តន៍មានចំនួនតិច។<br>-ការចំណាយលើការបង្កើនចំនួនអធិការកិច្ចនិងការពង្រឹងការអនុវត្តន៍មានចំនួនច្រើនគួរឲ្យកត់សម្គាល់។ |

| | | |
|---|---|---|
| ជម្រើសទី៤ : បង្កើនការធ្វើអធិការកិច្ចនិងឲ្យបានតឹងរឹងជាងមុនដោយផ្អែកលើលក្ខខណ្ឌតម្រូវដែលមានស្រាប់ | គួរឲ្យកត់សម្គាល់ | បន្ទុកចំណាយ ៩៦ ៩១០ ដុល្លារ(ប៉ាន់ស្មាន)នៅឆ្នាំទី១ ដែលភាគច្រើននៃចំនួននេះនឹងកើតឡើងផ្ទួននៅឆ្នាំនីមួយៗ។ |

## ៤.៤. ប៉ាន់ស្មានកម្រិតនៃផលចំណេញ

| ជម្រើស | កម្រិតនៃផលចំណេញ | មូលហេតុ |
|---|---|---|
| ជម្រើសទី១ : ប្រកាស | គួរឲ្យកត់សម្គាល់ | គោលការណ៍ណែនាំបច្ចេកទេសលម្អិតស្ដីពីរបៀបត្រួតពិនិត្យសំណល់រាវ ដែលគួរតែបង្កើនការយល់ដឹងបច្ចេកទេស ស្ដីពីការគ្រប់គ្រងសំណល់ រួមជាមួយទណ្ឌកម្មចំពោះការមិនអនុវត្តតាមគោលការណ៍នេះ ត្រូវបានព្យាករណ៍ថា ការអនុវត្តតាមច្បាប់ដែលមានស្រាប់នឹងកើនឡើងច្រើន ឧទាហរណ៍ តាមរយៈការកាត់បន្ថយភាពគ្រោះថ្នាក់នៃការបញ្ចេញចោលនៅពេលឧបករណ៍សម្ភារៈឬមធ្យោបាយប្រព្រឹត្តិកម្មបឋម បរាជ័យ។ កម្រិតនៃផលចំណេញមិនច្បាស់លាស់ ដោយមិនមានលទ្ធភាពព្យាករណ៍ពីចំនួននៃភាពគ្រោះថ្នាក់នៃការបញ្ចេញចោលសំណល់ដែលអាចកើតមានឡើង។ ទោះបីជាយ៉ាងក្ដី ប្រសិនបើវាអាចទប់ស្កាត់ សូម្បីតែមួយករណីនៃការបញ្ចេញសំណល់ចោលប្រកបដោយភាពគ្រោះថ្នាក់ខ្លាំង ក៏វានឹងផ្ដល់ផលចំណេញច្រើនដែរ។<br>ការនេះនឹងកាត់បន្ថយការបំពុលប្រភពទឹកសាធារណៈ កាត់បន្ថយភាពបង្កគ្រោះថ្នាក់ដល់ជីវចម្រុះ និងរួមចំណែកក្នុងការទាក់ទាញទេសចរអន្តរជាតិ។ |

| | | |
|---|---|---|
| | | ដែលជាប្រភពចំណូលថវិកាជាតិយ៉ាងសំខាន់។ |
| ជម្រើសទី២ : បង្កើនទណ្ឌកម្ម(សេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យការបំពុលបរិស្ថាន) | គួរឲ្យកត់សម្គាល់ | ទណ្ឌកម្មធ្ងន់ជាងមុនដែលមានចែងនៅក្នុងច្បាប់អាចធ្វើឲ្យមានការគោរពតាមលក្ខខណ្ឌតម្រូវដែលមានស្រាប់ច្រើនជាងមុន ដូចដែលបានរៀបរាប់ខាងលើនេះ។ ទោះបីជាយ៉ាងណា កង្វះគោលការណ៍ណែនាំបច្ចេកទេសអាចបន្ថយលទ្ធភាពក្នុងការកាត់បន្ថយការបំពុលទឹក។ ជាពិសេស ការបង្កើនទណ្ឌកម្មអាចមានឥទ្ធិពលតិចតួចក្នុងការកាត់បន្ថយការបញ្ចេញចោលសំណល់ប្រកបដោយភាពគ្រោះថ្នាក់ ដោយភាពកង្វះខាតឧបករណ៍សម្ភារៈឬមធ្យោបាយប្រព្រឹត្តកម្ម/រក្សាទុក។ |
| ជម្រើសទី៣ : បង្កើនទណ្ឌកម្ម និង ធ្វើការវាយតម្លៃផលប៉ះពាល់បរិស្ថានឲ្យបានម៉ត់ចត់ជាងមុន(សេចក្តីព្រាងច្បាប់EIA) | គួរឲ្យកត់សម្គាល់ | ទណ្ឌកម្មធ្ងន់ជាងមុនដែលមានចែងនៅក្នុងច្បាប់អាចធ្វើឲ្យមានការគោរពតាមលក្ខខណ្ឌតម្រូវEIAដែលមានស្រាប់ច្រើនជាងមុន។ ទោះបីជាយ៉ាងណាក្តី ដូចជម្រើសទី២ កង្វះខាតគោលការណ៍ណែនាំបច្ចេក ទេសទាក់ទងនឹងការរក្សាទុន និងការសំអាតសំណល់រាវអាចបន្ថយផលចំណេញ។ |
| ជម្រើសទី៤ : បង្កើនការធ្វើអធិការកិច្ចនិងឲ្យបានតឹងរឹងជាងមុនដោយផ្អែកលើលក្ខខណ្ឌតម្រូវដែលមានស្រាប់ | គួរឲ្យកត់សម្គាល់/មិនគួរឲ្យកត់សម្គាល់ | មិនច្បាស់លាស់(ត្រូវការពិគ្រោះយោបល់) |

## ៤.៥. តើមានផលប៉ះពាល់ដល់ការប្រជែងដែរឬទេ? មាន

SME អាចនឹងមិនមានលទ្ធភាពចំណាយលើការសាងសង់អាង ប្រព្រឹត្តកម្មទេ ដូចនេះពួកគេអាចនឹងចាកចេញពីទីផ្សារ។ ម្យ៉ាងទៀត សំណើប្រកាសអាចនឹងបង្កើនរបាំងក្នុងការចូលទីផ្សារ។ ដូច្នេះ

| |
|---|
| ហើយ រោងចក្រសហគ្រាសធំមួយចំនួនតូចនឹងគ្រប់គ្រងទីផ្សារ។ ការថយចុះនៃការប្រកួតប្រជែង អាចធ្វើថ្លៃទំនិញកើនឡើង សេវាកម្មនិងគុណភាពធ្លាក់ចុះ ។ |

## ៤.៦. តើមានផលប៉ះពាល់លើសមធម៌យេនឌ័រដែរឬទេ? មិនមាន

## ៥. កិច្ចពិគ្រោះយោបល់បឋម

| ក្រុម | សហគ្រាស | វិធីសាស្ត្រ | សង្ខេបទស្សនៈ |
|---|---|---|---|
| ធុរកិច្ច | | | មិនមានកិច្ចពិគ្រោះយោបល់ជាមួយធុរកិច្ចទេ។ កិច្ចពិគ្រោះយោបល់គួរធ្វើឡើងដែលជាផ្នែកមួយនៃការរៀនចំ RIS។ |
| រដ្ឋាភិបាល | នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាននៃក្រសួងបរិស្ថាន | ការិយាល័យ | លោក យិន សំរាយ បាននិយាយជាមួយ លោក ជា ស៊ីណា និងលោក ប៉ាន់ បូណុច អនុប្រធាននាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន ដោយលោកទាំងពីរបាននិយាយថា មន្ត្រីជំនាញនៅក្នុងនាយកដ្ឋាន បានពិនិត្យ និងយកសំណាកទឹក ពីរោងចក្រដែលមានការប្រើបាស់សារធាតុគីមីពុលរៀងរាល់បីខែម្តង ដោយឡែករោងចក្រអេតាណុល នៅព្រៃកក្តៅគឺយកសំណាកទឹកមកពិនិត្យរាល់ខែ ។<br>មន្ត្រីជំនាញនៅក្នុងនាយកដ្ឋានយកសំណាកទឹកពីរោងចក្រមកពិនិត្យនៅត្រង់ចំណុចដែលរោងចក្របញ្ចេញទឹកមកប្រភពទឹកសាធារណៈ។<br>ចំណែកការសាងសង់អាងប្រព្រឹត្តកម្មមន្ត្រីជំនាញនៅក្នុងនាយកដ្ឋាន មិនមានគោលការណ៍ណែនាំបច្ចេកទេសឲ្យម្ចាស់រោងចក្រសាងសង់អាងប្រព្រឹត្តកម្មទេ ។ រោងចក្រដែលប្រើប្រាស់សារធាតុគីមីពុលមួយចំនួនមិនបានរាយការណ៍ក្នុងការប្រើប្រាស់សាធាតុគីមី មកពីក្រសួងបរិស្ថានទេ ។ |

## ៦. សន្និដ្ឋាន

### ៦.១ សេចក្តីសង្ខេបនៃការចំណាយបន្ថែម និងផលចំណេញ

| ជម្រើស | បន្ទុកចំណាយរបស់វិស័យឧស្សាហកម្ម | បន្ទុកចំណាយរបស់វិស័យសាធារណៈ | ផលចំណេញ |
|---|---|---|---|
| ជម្រើសទី១ : ប្រកាស | គួរឲ្យកត់សម្គាល់ | មិនគួរឲ្យកត់សម្គាល់ | គួរឲ្យកត់សម្គាល់ |
| ជម្រើសទី២ : បង្កើនទណ្ឌកម្ម(សេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យការបំពុលបរិស្ថាន) | គួរឲ្យកត់សម្គាល់ | មិនគួរឲ្យកត់សម្គាល់ | គួរឲ្យកត់សម្គាល់ |
| ជម្រើសទី៣ : បង្កើនទណ្ឌកម្ម និង ធ្វើការវាយតម្លៃផលប៉ះពាល់បរិស្ថានឲ្យបានម៉ត់ចត់ជាងមុន (សេចក្តីព្រាងច្បាប់ EIA) | គួរឲ្យកត់សម្គាល់ | គួរឲ្យកត់សម្គាល់ | គួរឲ្យកត់សម្គាល់ |
| ជម្រើសទី៤ : បង្កើនការធ្វើអធិការកិច្ចនិងឲ្យបានតឹងរឹងជាងមុន ដោយផ្អែកលើលក្ខខណ្ឌតម្រូវដែលមានស្រាប់ | គួរឲ្យកត់សម្គាល់ | គួរឲ្យកត់សម្គាល់ | មិនច្បាស់លាស់ |

៦.២. តើចាំបាច់ធ្វើ RIS ដែរឬទេ? ចាំបាច់

| |
|---|
| សំណើប្រកាសមានបន្ទុកចំណាយកាតព្វកិច្ចខ្ពស់។ |

៦.៣. ជម្រើសដែលបានជ្រើសរើស (សូមអធិប្បាយអំពីជម្រើស)

| |
|---|
| |

| លក្ខណៈវិនិច្ឆ័យ | | មូលហេតុ |
|---|---|---|
| តើវាជាជម្រើសដែលមានបន្ទុកចំណាយអប្បបរមាសម្រាប់វិស័យឧស្សាហកម្ម ដែរឬទេ? | មែន/ទេ | |
| តើជម្រើសនេះផ្តល់នូវផលចំណេញអតិបរមាដែរឬទេ? | មែន/ទេ | |
| តើវាជាជម្រើសដែលមានហានិភ័យអប្បបរមាសម្រាប់សាធារណៈដែរឬទេ? | មែន/ទេ | |

តើមានកត្តាអ្វីផ្សេងទៀត ដែលអាចប្រើប្រាស់ដើម្បីជ្រើសរើសជម្រើសនេះឬទេ? ទេ

## ៧. ការអនុវត្តន៍

ប្រសិនបើជម្រើសបញ្ញត្តិកម្មត្រូវបានជ្រើសរើស៖

៧.១. តើវិធានការអ្វីត្រូវបានជ្រើសរើស ដើម្បីលើកកម្ពស់តម្លាភាព និងអភិបាលកិច្ចល្អក្នុងអំឡុងពេលនៃការប្រតិបត្តិ?

៧.២. តើគួរធ្វើការពិនិត្យបញ្ញត្តិកម្មនេះឡើងវិញក្រោយពេលបញ្ញត្តិកម្មនេះត្រូវបានប្រតិបត្តិដែរឬទេ? បើដូច្នោះ តើបញ្ញត្តិកម្មនេះគួរត្រូវបានពិនិត្យឡើងវិញយ៉ាងដូចម្តេច និងនៅពេលណា?

អត្ថាធិប្បាយផ្សេងទៀត.

| ដំណើរការ | ឈ្មោះ | តួនាទី | ហត្ថលេខា | កាលបរិច្ឆេទ |
|---|---|---|---|---|
| រៀបចំដោយ (ក្រសួងពាក់ព័ន្ធ) | [illegible] | ប្រធាន RIA (MOE) | [signature] | 23.05.13 |
| ត្រួតពិនិត្យដោយ (ORIA) | ស៊ឹម សុខេន | សមាជិក RIA | [signature] | 27.05.13 |
| | [illegible] | [illegible] RIA | [signature] | 27.05.13 |
| | ប៉ែម សារិទ្ធ | ប្រធានផ្នែក CBA | [signature] | 29.05.13 |
| ឯកភាពដោយ (ORIA) | ម៉ែន សុខា | អ្នកគ្រប់គ្រងគម្រោង | [signature] | 30.05.13 |
| បញ្ចូលទិន្នន័យដោយ | ស៊ឹម សុខេន | សមាជិក RIA | [signature] | 27.05.13 |
| បញ្ចូលក្នុងគេហទំព័រដោយ | ឈៀប វណ្ណា | សមាជិក I-Center | [signature] | 31.05.13 |